**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:........✓.......

# សេចក្តីប្រកាសព័ត៌មាន

ដើម្បីប្រុងប្រៀបរៀបចំជូនកិច្ចប្រជុំផ្លូវការលើកទី១២នៃ **គណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ** (General Border Committee GBC)ក្រុមលេខាធិការដ្ឋាន **គណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ** (General Border Committee Secretariat or GBCS) នឹងដំណើរការកិច្ចប្រជុំរបស់ខ្លួន ចាប់ពីថ្ងៃទី២៧ ខែកុម្ភៈ ដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ នៅខេត្តសៀមរាប ។

គោលដៅនៃកិច្ចប្រជុំខាងលើគឺ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងកងទ័ពនៃប្រទេសទាំងពីរ កម្ពុជា-ថៃ ពិសេសក្នុងការរក្សាសន្តិភាព ស្ថេរភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ ដើម្បីទប់ស្កាត់និងបង្ក្រាបរាល់សកម្មភាពខុសច្បាប់នានា នៅតំបន់ព្រំដែនរួមមាន៖ បញ្ហារត់ពន្ធគ្រឿងញៀន រត់ពន្ធមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែននានា ដែលភាគីទាំងពីរនឹងពុះពារស្វែងរកដំណោះស្រាយ និងមានវិធានការទប់ស្កាត់ ដើម្បីរក្សា និងធានាបាននូវស្ថេរភាព សន្តិសុខ និងការអភិវឌ្ឍន៍នៅតាមបណ្តាយព្រំដែនរួម នៃប្រទេសជិតខាងទាំងពីរ។

កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំផ្លូវការលើកទី១២នៃ **គណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ** (General Border Committee GBC) ដែលនឹងប្រព្រឹត្តទៅនា ខែមីនា ឆ្នាំ២០១៧ ខាងមុខ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧